ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៩៤ ព.ណ[illegible]

# សេចក្តីសម្រេច
# ស្តីពី
# បែបបទនិងនីតិវិធីនៃការគណនាប្រាក់ផាកពិន័យ
# ចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១.- គោលបំណង

សេចក្តីសម្រេចនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការគណនាប្រាក់ផាកពិន័យ ចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដើម្បីធានាបាននូវតម្លាភាព សុក្រឹតភាព និងប្រសិទ្ធភាពនៃការគណនាប្រាក់ផាកពិន័យ ព្រមទាំងបង្ការការព្រមព្រៀងឬសកម្មភាពដែលរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់នៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។

### ប្រការ២.- វិសាលភាព

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះការគណនាប្រាក់ផាកពិន័យ ដែលត្រូវយកមកអនុវត្តចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

### ប្រការ៣.- ស្ថាប័នមានសមត្ថកិច្ច

គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគណនាប្រាក់ផាកពិន័យចំពោះបទល្មើសក្រោមច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដែលមានអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» ជាសេនាធិការ។

### ប្រការ៤.- នីតិវិធីនៃការគណនាប្រាក់ផាកពិន័យ

គ.ប.ក. ត្រូវអនុវត្តនីតិវិធីនៃការគណនាប្រាក់ផាកពិន័យតាមដំណាក់កាល ដូចខាងក្រោម៖

១.ការគណនាប្រាក់ផាកពិន័យកំណត់ដោយច្បាប់។

២.ការគណនាប្រាក់ផាកពិន័យគោល។

៣.ការកែតម្រូវប្រាក់ផាកពិន័យគោលតាមស្ថានទម្ងន់ និងស្ថានសម្រាល។

៤.ការកែតម្រូវប្រាក់ផាកពិន័យគោលតាមប្រាក់ផាកពិន័យកំណត់ដោយច្បាប់។

៥.ការកែតម្រូវចុងក្រោយ។

ក្នុងករណីដែលបុគ្គលប្រព្រឹត្តបទល្មើសដដែលៗច្រើនដង ឬប្រព្រឹត្តបទល្មើសផ្សេងគ្នាក្នុងពេលតែមួយ ហើយមិនទាន់ធ្លាប់ទទួលបានការព្រមានជាលាយលក្ខណ៍អក្សរឬការផាកពិន័យជាប្រាក់លើបទល្មើសនោះ ការគណនាប្រាក់ផាកពិន័យជាប្រាក់ត្រូវកំណត់ចំពោះការបំពាននីមួយៗដាច់ដោយឡែកពីគ្នា ឬតាមការសម្រេចផ្សេងពីនេះដោយ គ.ប.ក.។

## ជំពូកទី៣
## ការគណនាប្រាក់ផាកពិន័យកំណត់ដោយច្បាប់

### ប្រការ៥.- ការគណនាប្រាក់ផាកពិន័យកំណត់ដោយច្បាប់

អនុលោមតាមមាត្រា៣៥នៃច្បាប់ស្តីពីការប្រកួតប្រជែង ប្រាក់ផាកពិន័យកំណត់ដោយច្បាប់ គឺជាប្រាក់ផាកពិន័យអប្បបរមា និងអតិបរមា ដែលត្រូវគណនាក្នុងអត្រាពី ៣% ទៅ ១០% នៃផលរបរសរុបរបស់បុគ្គលគុណនឹង៣(បី)ឆ្នាំ ឬចំនួនឆ្នាំនិងខែជាក់ស្តែង ក្នុងករណីដែលរយៈពេលនៃការបំពានមានថិរវេលាតិចជាង៣(បី)ឆ្នាំ។

### ប្រការ៦.- ការកំណត់ផលរបរសរុប

ផលរបរសរុបរបស់បុគ្គល ត្រូវយកផលរបរសរុបនៃឆ្នាំហិរញ្ញវត្ថុណាមួយដែលមានចំនួនខ្ពស់បំផុត ក្នុងរយៈពេលនៃការបំពាន ដែលផលរបរសរុបសំដៅដល់ផលរបររបស់បុគ្គលក្នុងឆ្នាំហិរញ្ញវត្ថុណាមួយ មុនពេលកាត់កងប្រាក់បង្វិលនៃការលក់ អាករលើតម្លៃបន្ថែម និងពន្ធដទៃទៀតដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការលក់ ចំណែកឯផលរបរសំដៅដល់តម្លៃនៃការលក់ទំនិញឬសេវារបស់បុគ្គល ដែលជាសកម្មភាពធុរកិច្ចទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីបុគ្គលគឺជាផ្នែកនៃក្រុម ផលរបរសរុបត្រូវគណនាដោយការបូកបញ្ចូលគ្នានូវផលរបរសរុបខ្ពស់បំផុតរបស់បុគ្គលទាំងអស់នៅក្នុងក្រុម។ ផលរបរដែលកើតចេញពីការលក់ទំនិញនិងសេវារវាងបុគ្គលស្ថិតនៅក្នុងក្រុមតែមួយមិនត្រូវយកមកបូកបញ្ចូលឡើយ។

ក្នុងករណីបុគ្គលគឺជាសមាជិកនៃសមាគម ផលរបរសរុបត្រូវគណនាដោយបូកបញ្ចូលគ្នានូវផលរបរសរុបខ្ពស់បំផុតរបស់សមាជិកទាំងអស់នៃសមាគម ដែលសមាគមសំដៅដល់សមាគមរកប្រាក់ចំណេញ ឬមិនរកប្រាក់ចំណេញ ដែលមានជាអាទិ៍ សមាគមពាណិជ្ជកម្ម សភាពាណិជ្ជកម្ម ឬគ្រឹះស្ថានផ្សេងៗ ដែលតំណាងការពារ និងលើកកម្ពស់ផលប្រយោជន៍សមាជិករបស់ខ្លួននិងវិស័យពាក់ព័ន្ធរបស់ខ្លួន ទោះជាបានចុះបញ្ជីឬមិនបានចុះបញ្ជីក្នុងប្រទេសឬក្រៅប្រទេសក្តី។

ក្នុងករណីពុំមានតួលេខផលរបរសរុបសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលត្រូវបានជ្រើសរើស ឬ **គ.ប.ក.** យល់ឃើញថាតួលេខដែលបុគ្គលផ្តល់ឱ្យពុំបានបង្ហាញពីសកម្មភាព ឬប្រតិបត្តិការធុរកិច្ចជាក់ស្តែងរបស់បុគ្គលនោះទេ **គ.ប.ក.** មានឆន្ទានុសិទ្ធិក្នុងការជ្រើសយកឆ្នាំណាមួយផ្សេងទៀត ឬប្រើប្រាស់តួលេខដទៃទៀតសម្រាប់ធ្វើការគណនាប្រាក់ផាកពិន័យកំណត់ដោយច្បាប់។

### ប្រការ៧.- ការកំណត់រយៈពេលនៃការបំពាន

ក្នុងករណីការបំពានមានរយៈពេលតិចជាង៣(បី)ឆ្នាំ រយៈពេលនៃការបំពានត្រូវកំណត់តាមចំនួនឆ្នាំ និង/ឬខែជាក់ស្តែងដូចខាងក្រោម៖

១. ការបំពានត្រូវចាត់ទុកថាមានរយៈពេល៦(ប្រាំមួយ)ខែ ប្រសិនបើការបំពានមានរយៈពេលតិចជាង៦(ប្រាំមួយ)ខែ។

២. ការបំពានត្រូវចាត់ទុកថាមានរយៈពេល១(មួយ)ឆ្នាំ ប្រសិនបើការបំពានមានរយៈពេលពី៦(ប្រាំមួយ)ខែទៅ១២(ដប់ពីរ)ខែ។

គ.ប.ក. ត្រូវកំណត់កាលបរិច្ឆេទនៃការចាប់ផ្ដើមនិងការបញ្ចប់នៃការបំពានទៅតាមករណីនីមួយៗ ដោយធ្វើការពិចារណាលើអង្គហេតុ និងស្ថានភាពជាក់ស្ដែង។

## ជំពូកទី៤

## ការគណនាប្រាក់ផាកពិន័យគោល

### ប្រការ៨.- ការគណនាប្រាក់ផាកពិន័យគោល

ប្រាក់ផាកពិន័យគោលត្រូវបានគណនា ដោយយកអត្រាភាគរយណាមួយដែលកំណត់ដោយ **គ.ប.ក.** គុណនឹងផលរបរពាក់ព័ន្ធរបស់បុគ្គល គុណនឹងរយៈពេលនៃការបំពាន។

ដំណាក់កាលនៃការគណនាប្រាក់ផាកពិន័យគោលមានដូចខាងក្រោម៖

១. កំណត់អត្រាភាគរយដែលកំណត់ដោយ **គ.ប.ក.**។

២. កំណត់ផលរបរពាក់ព័ន្ធខ្ពស់បំផុតក្នុងរយៈពេលនៃការបំពាន។

៣. កំណត់រយៈពេលនៃការបំពាន។

### ប្រការ៩.- ការកំណត់អត្រាភាគរយ

**គ.ប.ក.** មានឆន្ទានុសិទ្ធិក្នុងការកំណត់អត្រាភាគរយដែលត្រូវយកមកគុណនឹងផលរបរពាក់ព័ន្ធ ដោយធ្វើការពិចារណាលើភាពធ្ងន់ធ្ងរនៃការបំពាន និងកត្តាផ្សេងៗ។

### ប្រការ១០.- ការកំណត់ផលរបរពាក់ព័ន្ធ

ផលរបរពាក់ព័ន្ធរបស់បុគ្គល ត្រូវយកផលរបរពាក់ព័ន្ធនៃឆ្នាំហិរញ្ញវត្ថុណាមួយដែលមានចំនួនខ្ពស់បំផុតក្នុងរយៈពេលនៃការបំពាន ដែលផលរបរពាក់ព័ន្ធសំដៅដល់ផលរបររបស់បុគ្គលក្នុងឆ្នាំហិរញ្ញវត្ថុណាមួយនៅក្នុងទីផ្សារពាក់ព័ន្ធដែលទទួលរងផលប៉ះពាល់ដោយការបំពាន មុនពេលកាត់កងប្រាក់បង្វិលនៃការលក់ អាករលើតម្លៃបន្ថែម និងពន្ធដទៃទៀតដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការលក់។

ក្នុងករណីពុំមានតួលេខផលរបរពាក់ព័ន្ធសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលត្រូវបានជ្រើសរើស ឬ **គ.ប.ក.** យល់ឃើញថាតួលេខដែលបុគ្គលផ្ដល់ឱ្យពុំបានបង្ហាញពីសកម្មភាព ឬប្រតិបត្តិការធុរកិច្ចជាក់ស្ដែងរបស់បុគ្គលនោះទេ **គ.ប.ក.** មានឆន្ទានុសិទ្ធិក្នុងការជ្រើសយកឆ្នាំណាមួយផ្សេងទៀត ឬប្រើប្រាស់តួលេខដទៃទៀតសម្រាប់ធ្វើការគណនាប្រាក់ផាកពិន័យគោល។

ក្នុងករណីពុំទាន់មានផលរបរពាក់ព័ន្ធ ផលរបរពាក់ព័ន្ធនឹងត្រូវគណនាពីផលរបរនៃឆ្នាំហិរញ្ញវត្ថុមុនឆ្នាំនៃការបំពានកើតឡើង។

**ប្រការ១១.- ការកំណត់រយៈពេលនៃការបំពាន**

រយៈពេលនៃការបំពានត្រូវកំណត់តាមចំនួនឆ្នាំនិងខែជាក់ស្តែងដូចខាងក្រោម៖

១. ការបំពានត្រូវចាត់ទុកថាមានរយៈពេល៦(ប្រាំមួយ)ខែ ប្រសិនបើការបំពានមានរយៈពេលតិចជាង ៦(ប្រាំមួយ)ខែ។

២. ការបំពានត្រូវចាត់ទុកថាមានរយៈពេល១(មួយ)ឆ្នាំ ប្រសិនបើការបំពានមានរយៈពេលពី ៦(ប្រាំមួយ)ខែទៅ១២(ដប់ពីរ)ខែ។

គ.ប.ក. ត្រូវកំណត់កាលបរិច្ឆេទនៃការចាប់ផ្តើម និងការបញ្ចប់នៃការបំពានទៅតាមករណីនីមួយៗ ដោយធ្វើការពិចារណាលើអង្គហេតុ និងស្ថានភាពនៃករណីជាក់ស្តែង។

## ជំពូកទី៥
## ការកែតម្រូវ

**ប្រការ១២.- ការកែតម្រូវចំនួនប្រាក់ផាកពិន័យគោលផ្អែកលើស្ថានទម្ងន់ និងស្ថានសម្រាល**

ប្រាក់ផាកពិន័យគោលអាចត្រូវបានតម្លើង ឬបន្ថយផ្អែកលើស្ថានទម្ងន់ និងស្ថានសម្រាល ក្នុងករណីនីមួយៗដូចខាងក្រោម៖

**ក. ស្ថានទម្ងន់**

១. ការរៀបចំទុកជាមុនដែលមានផែនការច្បាស់លាស់។

២. តួនាទីរបស់បុគ្គលក្នុងនាមជាអ្នកដឹកនាំ ឬអ្នកប្រព្រឹត្តបទល្មើស។

៣. ការចូលរួមរបស់អភិបាល ឬអ្នកគ្រប់គ្រងជាន់ខ្ពស់។

៤. វិធានការបង្ខំ ឬគាបសង្កត់ធ្វើឡើងចំពោះបុគ្គលដទៃដើម្បីឱ្យបន្តប្រព្រឹត្តបទល្មើស។

៥. ការបន្តការបំពានក្នុងដំណាក់កាលត្រួតពិនិត្យបឋម និងស៊ើបអង្កេត។

៦. ការរារាំង ឬមិនសហការក្នុងដំណាក់កាលត្រួតពិនិត្យបឋម និងស៊ើបអង្កេត។

៧. ការបំពានដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនា ជាជាងការធ្វេសប្រហែស។

៨. ការប្រព្រឹត្តអំពើបំពានដោយបុគ្គលដដែលចំពោះបទល្មើសផ្សេងគ្នា។

៩. ការប្រព្រឹត្តអំពើបំពានដូចគ្នាច្រើនដង មុនពេលទទួលបានការព្រមានជាលាយលក្ខណ៍អក្សរ និងការផាកពិន័យជាប្រាក់។

១០. ការប្រព្រឹត្តអំពើបំពានដោយបុគ្គលក្នុងក្រុមតែមួយទៅលើបទល្មើសដដែលៗ។

១១. ការខកខានដោយគ្មានមូលហេតុត្រឹមត្រូវក្នុងការផ្តល់ព័ត៌មានហិរញ្ញវត្ថុ ផលរបរសុប ផលរបរពាក់ព័ន្ធ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

១២. ទំហំធុរកិច្ចនៃបុគ្គលបំពានច្បាប់។

១៣. ការឆ្លៀតឱកាសរបស់បុគ្គលក្នុងស្ថានភាពសង្គ្រាម ការដាក់ប្រទេសជាតិក្នុងភាពអាសន្ន គ្រោះធម្មជាតិ ការរាលដាលនៃជំងឺឆ្លង ឬស្ថានភាពដទៃទៀតដើម្បីប្រព្រឹត្តបទល្មើស។

១៤. កត្តាផ្សេងទៀតទៅតាមអង្គហេតុ និងស្ថានភាពនៃករណីនីមួយៗ។

ខ. ស្ថានសម្រាល

១. ការរៀបចំទុកជាមុនដែលមានផែនការច្បាស់លាស់ ហើយត្រូវបានធ្វើឡើងក្រោមការគំរាមកំហែង ឬការដាក់សម្ពាធធ្ងន់ធ្ងរ។

២. ការប្រព្រឹត្តបទល្មើសលើកដំបូង ដែល **គ.ប.ក.** ត្រូវពិចារណាទៅលើផលប៉ះពាល់នៃការបំពាននេះទៅតាមករណីជាក់ស្តែង។

៣. ការដាក់ចេញនូវកម្មវិធីអនុលោមភាពធុរកិច្ចនានា។

៤. ការចាត់វិធានការសមស្របក្នុងការធានាឱ្យមានអនុលោមភាពស្របតាមច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិពាក់ព័ន្ធនានា។

៥. ការអនុវត្តសកម្មភាពណាមួយ ដើម្បីបង្ការឬកាត់បន្ថយផលប៉ះពាល់ដែលកើតចេញពីការបំពាន ឬបានស្ម័គ្រចិត្តផ្តល់សំណងសម្រាប់ការខូចខាត ឬស្ម័គ្រចិត្តក្នុងការអនុវត្តវិធានការផ្សេងៗ។

៦. ការបញ្ចប់ការបំពាននៅក្នុងដំណាក់កាលត្រួតពិនិត្យបឋម និងស៊ើបអង្កេត។

៧. កិច្ចសហការ និងការផ្តល់ជំនួយដែលជំរុញឱ្យដំណើរការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង និងបទប្បញ្ញត្តិពាក់ព័ន្ធកាន់តែមានប្រសិទ្ធភាព។

៨. កត្តាផ្សេងទៀតទៅតាមអង្គហេតុ និងស្ថានភាពនៃករណីនីមួយៗ។

## ប្រការ១៣.- ការកែតម្រូវប្រាក់ផាកពិន័យគោលតាមប្រាក់ផាកពិន័យកំណត់ដោយច្បាប់

បន្ទាប់ពីធ្វើការកែតម្រូវផ្អែកលើស្ថានទម្ងន់ និងស្ថានសម្រាល ប្រាក់ផាកពិន័យគោលត្រូវបានកែតម្រូវបន្ថែមទៀតទៅតាមប្រាក់ផាកពិន័យកំណត់ដោយច្បាប់ ដូចមានចែងក្នុងប្រការ៥នៃសេចក្តីសម្រេចនេះ។

## ប្រការ១៤.- ការកែតម្រូវចុងក្រោយ

បន្ទាប់ពីធ្វើការកែតម្រូវទៅតាមប្រាក់ផាកពិន័យកំណត់ដោយច្បាប់ **គ.ប.ក.** ត្រូវធ្វើការកែតម្រូវប្រាក់ផាកពិន័យគោល ក្នុងករណីបុគ្គលបំពានច្បាប់បានចូលរួមដោះស្រាយតាមការចរចាដែលទទួលបានជោគជ័យ ស្របតាមប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការដោះស្រាយតាមការចរចាក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

ក្នុងករណីចាំបាច់ **គ.ប.ក.** អាចបន្ថយចំនួនប្រាក់ផាកពិន័យ ដោយធ្វើការពិចារណាលើលទ្ធភាពក្នុងការបង់ប្រាក់ផាកពិន័យរបស់បុគ្គលបំពានច្បាប់ ដោយផ្អែកលើស្ថានភាពសង្គមនិងសេដ្ឋកិច្ចជាក់លាក់ណាមួយ។ ការកាត់បន្ថយប្រាក់ផាកពិន័យនេះមិនត្រូវបានផ្តល់ឱ្យនោះទេ ដោយគ្រាន់តែបុគ្គលបំពានច្បាប់នោះស្ថិតក្នុងស្ថានភាពខាតបង់ផ្នែកហិរញ្ញវត្ថុនោះ។ ការកាត់បន្ថយប្រាក់ផាកពិន័យនេះអាចត្រូវ

បានផ្តល់ ក្នុងករណីដែលមានភស្តុតាងជាសត្យានុម័តបញ្ជាក់ថា ការផាកពិន័យជាប្រាក់នេះនឹងនាំឱ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពរស់រានផ្នែកសេដ្ឋកិច្ច ដែលមិនអាចស្រោចស្រង់បាន។

ការបន្ថយប្រាក់ផាកពិន័យផ្សេងទៀត ត្រូវកំណត់តាមឆន្ទានុសិទ្ធិរបស់ **គ.ប.ក.** និងស្របតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

### ប្រការ១៥.- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ១៦.- ការអនុវត្ត

សមាសភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៥កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ